ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ : ១៦១ អនក្រ.បក**

# អនុក្រឹត្យ
## ស្ដីពី
## ការកែប្រែតំបន់ប្រើប្រាស់ច្រើនយ៉ាងសសរស្ដម្ភសត្វតោ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្ដីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីកិច្ចការពារបរិស្ថាននិងការគ្រប់គ្រងធនធានធម្មជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីព្រៃឈើ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៦/០១១ ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីជលផល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០៨/០០៧ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីតំបន់ការពារធម្មជាតិ
- បានឃើញអនុក្រឹត្យលេខ២៣៤ អនក្រ.បក ចុះថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០២១ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន

- បានឃើញអនុក្រឹត្យលេខ២០១ អនក្រ.បក ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៧ ស្តីពីការបង្កើតតំបន់ប្រើប្រាស់ច្រើនយ៉ាងសសរស្តម្ភសត្វតោ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងបរិស្ថាន

## សម្រេច

**មាត្រា១ .-**

ត្រូវបានកែប្រែតំបន់ប្រើប្រាស់ច្រើនយ៉ាងសសរស្តម្ភសត្វតោ ពីផ្ទៃដីទំហំ៨៣៩(ប្រាំបីរយសាមសិបប្រាំបួន)ហិកតា មកផ្ទៃដីទំហំ៥ ៣២៧(ប្រាំពាន់បីរយម្ភៃប្រាំពីរ)ហិកតា ស្ថិតក្នុងភូមិសាស្ត្រខេត្តក្រចេះ ដូចមានផែនទីភ្ជាប់ក្នុងឧបសម្ព័ន្ធ១និងនិយាមកា(តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum WGS. 1984)ភ្ជាប់ក្នុងឧបសម្ព័ន្ធ២នៃអនុក្រឹត្យនេះ។

ផ្ទៃដីតំបន់ប្រើប្រាស់ច្រើនយ៉ាងសសរស្តម្ភសត្វតោខាងលើនេះ បានមកពីការបូកបញ្ចូលផ្ទៃដីទំហំ៨៣៩ (ប្រាំបីរយសាមសិបប្រាំបួន)ហិកតា ដែលមានចែងក្នុងអនុក្រឹត្យលេខ២០១ អនក្រ.បក ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៧ ស្តីពីការបង្កើតតំបន់ប្រើប្រាស់ច្រើនយ៉ាងសសរស្តម្ភសត្វតោ និងផ្នែកខ្លះនៃរបៀងអភិរក្សជីវៈចម្រុះព្រៃឡង់ ដែលមានផ្ទៃដីទំហំ៤ ៤៨៨(បួនពាន់បួនរយប៉ែតសិបប្រាំបី)ហិកតា ដូចមានចែងក្នុងអនុក្រឹត្យលេខ០៧ អនក្រ.បក ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០១៧ ស្តីពីការបង្កើតរបៀងអភិរក្សជីវៈចម្រុះប្រព័ន្ធតំបន់ការពារធម្មជាតិ។

**មាត្រា២ .-**

អនុក្រឹត្យនេះមានគោលបំណងដូចតទៅ៖

- ធានាថែរក្សាស្ថិរភាពនៃប្រព័ន្ធអេកូឡូស៊ី និងសារព័នមជ្ឈដ្ឋានធម្មជាតិ សម្រាប់ធនធានទឹក សត្វព្រៃ រុក្ខជាតិ ជាមួយនឹងទិដ្ឋភាពនៃការធានាអភិវឌ្ឍន៍សេដ្ឋកិច្ចដោយចីរភាព
- ផ្តល់ផលិតផលនិងសេវាកម្មធម្មជាតិសម្រាប់ប្រើប្រាស់តាមតម្រូវការរបស់សហគមន៍មូលដ្ឋាន
- ចូលរួមចំណែករក្សាលំនឹងបរិស្ថាននិងកាត់បន្ថយការប្រែប្រួលអាកាសធាតុនិងហានិភ័យគ្រោះមហន្តរាយធម្មជាតិ
- លើកកម្ពស់ការចូលរួមរបស់សហគមន៍មូលដ្ឋាន ក៏ដូចជាសាធារណជនក្នុងការចូលរួមចំណែកដល់ការគ្រប់គ្រង ការការពារ និងការអភិរក្សជីវៈចម្រុះ និងធនធានធម្មជាតិក្នុងតំបន់។

**មាត្រា៣ .-**

ក្រសួងបរិស្ថានមានសមត្ថកិច្ចរៀបចំ កែប្រែ និងគ្រប់គ្រងតំបន់ប្រើប្រាស់ច្រើនយ៉ាងសសរស្តម្ភសត្វតោ ដោយសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលខេត្តក្រចេះ ដើម្បីធានាដល់ការគ្រប់គ្រងបរិស្ថាន ការគ្រប់គ្រងជីវៈចម្រុះ ការប្រើប្រាស់ធនធានធម្មជាតិប្រកបដោយនិរន្តរភាព និងការរស់នៅដោយចីរភាព ស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

**មាត្រា៤ .-**

លិខិតបទដ្ឋានគតិយុត្តដែលពាក់ព័ន្ធនឹងការកំណត់តំបន់សហគមន៍ តំបន់ប្រើប្រាស់ដោយចីរភាព ការវិនិយោគ ការចេញប័ណ្ណដីធ្លី ឬការអនុញ្ញាតឱ្យប្រើប្រាស់ដីធ្លី ដែលអនុលោមតាមអនុក្រឹត្យស្តីពីការបង្កើតតំបន់ប្រើប្រាស់ច្រើនយ៉ាងសសរស្តម្ភសត្វតោ អនុក្រឹត្យស្តីពីការបង្កើតរបៀងអភិរក្សជីវៈចម្រុះប្រព័ន្ធតំបន់ការពារធម្មជាតិ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន ត្រូវមានអានុភាពអនុវត្តបន្តរហូតដល់មានលិខិតបទដ្ឋានគតិយុត្តថ្មីមកជំនួសស្របតាមបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ។

**មាត្រា៥ .-**

អនុក្រឹត្យលេខ០៧ អនក្រ.បក ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០១៧ ស្តីពីការបង្កើតរបៀងអភិរក្សជីវៈចម្រុះ ប្រព័ន្ធតំបន់ការពារធម្មជាតិ និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៦ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តក្រចេះ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃចន្ទ ១៥ រោច ខែបឋមាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ២០២៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រីសូមហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងបរិស្ថាន**

**សាយ សំអាល់**

**កន្លែងទទួល** :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៦
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ ១៦១ អនក្រ.បក ចុះថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ២០២៣

## ផែនទីតំបន់ប្រើប្រាស់ច្រើនយ៉ាង “សសរស្តម្ភសត្វតោ” ស្ថិតក្នុងភូមិសាស្ត្រខេត្តក្រចេះ







**សញ្ញាសម្គាល់**

- ចំណុចនិយាមកា
- ព្រំប្រទល់ខេត្ត
- ព្រំប្រទល់តំបន់ការពារធម្មជាតិ

មាត្រដ្ឋាន 1:45,000

0 1 2 km

Map Coordinate System:
Units: meters
System Projection: UTM, Zone 48 N
Datum: WGS 1984

**តំបន់ប្រើប្រាស់ច្រើនយ៉ាង «សសរស្តម្ភសត្វតោ»**

មានផ្ទៃដីទំហំ ៥ ៣២៧ហិកតា

**ប្រភពទិន្នន័យ**

| | |
|---|---|
| ព្រំប្រទល់តំបន់ការពារធម្មជាតិ | : ក្រសួងបរិស្ថាន |
| ព្រំប្រទល់ខេត្ត | : ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ (២០២១) |
| ប្រភព | : Google Earth |
| ផលិតដោយ | : នាយកដ្ឋានសេវាភូមិសាស្ត្រនៃក្រសួងបរិស្ថាន |

ឧបសម្ព័ន្ធ២នៃអនុក្រឹត្យលេខ ១៦១ អនក្រ.បក ចុះថ្ងៃទី ១៧ ខែកក្កដា ឆ្នាំ២០២៣

ចំណុចនិយាមកានៃផែនទីតំបន់ប្រើប្រាស់ច្រើនយ៉ាង«សសរស្តម្ភសត្វគោ»

| ID | X | Y |
|---|---|---|
| 1 | 663210 | 1436303 |
| 2 | 663859 | 1435987 |
| 3 | 664763 | 1435558 |
| 4 | 665891 | 1434990 |
| 5 | 666887 | 1434411 |
| 6 | 667747 | 1433900 |
| 7 | 668710 | 1433298 |
| 8 | 669762 | 1432603 |
| 9 | 670941 | 1431820 |
| 10 | 671901 | 1431119 |
| 11 | 672686 | 1430501 |
| 12 | 673439 | 1429842 |
| 13 | 674100 | 1429094 |
| 14 | 674528 | 1428414 |
| 15 | 673335 | 1428409 |
| 16 | 672335 | 1428407 |
| 17 | 671335 | 1428407 |
| 18 | 670335 | 1428407 |
| 19 | 669335 | 1428407 |
| 20 | 668507 | 1428407 |
| 21 | 667180 | 1429021 |
| 22 | 666058 | 1429541 |
| 23 | 665555 | 1430547 |
| 24 | 665195 | 1429937 |
| 25 | 664793 | 1430499 |
| 26 | 664023 | 1430623 |
| 27 | 663320 | 1430736 |
| 28 | 663197 | 1430250 |
| 29 | 663380 | 1429961 |
| 30 | 663184 | 1429885 |
| 31 | 663011 | 1430468 |
| 32 | 662638 | 1430725 |
| 33 | 662227 | 1430843 |
| 34 | 662156 | 1430697 |
| 35 | 662403 | 1430452 |
| 36 | 662751 | 1430454 |
| 37 | 662698 | 1429966 |
| 38 | 662864 | 1429767 |
| 39 | 661698 | 1429448 |
| 40 | 661205 | 1429896 |
| 41 | 660819 | 1430317 |
| 42 | 660922 | 1430587 |
| 43 | 661366 | 1430630 |
| 44 | 661378 | 1431368 |
| 45 | 661096 | 1431527 |
| 46 | 661417 | 1431733 |
| 47 | 661441 | 1431949 |
| 48 | 661580 | 1431876 |
| 49 | 661522 | 1432252 |
| 50 | 661284 | 1432054 |
| 51 | 661207 | 1432195 |
| 52 | 661114 | 1432040 |
| 53 | 661088 | 1432728 |
| 54 | 661522 | 1432810 |
| 55 | 661924 | 1433043 |
| 56 | 661924 | 1434232 |
| 57 | 662357 | 1434488 |
| 58 | 662720 | 1434834 |
| 59 | 662799 | 1435100 |
| 60 | 663210 | 1435340 |